**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ៣ ឆ្នាំ២០០៤

លេខ : ០៤/០៤...កបធ.ស.ជ.ណ

**សូមទូលថ្វាយ និង ជំរាបជូន**

**សម្តេចក្រុមឃុន ព្រះអង្គម្ចាស់ក្សត្រី អ្នកអង្គម្ចាស់ក្សត្រី ឯកឧត្តម**
**ជាតំណាងរាស្ត្រចំនួន ១៥ រូប**

សូមទ្រង់ជ្រាប និង ជ្រាប ។

**កម្មវត្ថុ** : ករណីសំណើសុំឱ្យបកស្រាយនូវសំណួរដែលពាក់ព័ន្ធនឹងការអនុវត្តន៍ច្បាប់រដ្ឋធម្មនុញ្ញ និង ច្បាប់ដទៃទៀត។
**យោង** : លិខិត ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៤ របស់ក្រុមតំណាងរាស្ត្រចំនួន ១៥ រូប។

តបតាមលិខិត ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៤ របស់ សម្តេចក្រុមឃុន ព្រះអង្គម្ចាស់ក្សត្រី អ្នកអង្គ-ម្ចាស់ក្សត្រី ឯកឧត្តម ដែលមានក្នុងកម្មវត្ថុ និង យោងខាងលើនេះ ខ្ញុំសូមទូលថ្វាយ និង ជម្រាបថា ក្រោយពីបានសិក្សាយ៉ាងហ្មត់ចត់ក្រុមប្រឹក្សាធម្មនុញ្ញ មានសេចក្តីសោកស្តាយដោយពុំអាចទទួលលិខិតខាងលើនេះ មកពិនិត្យបានពីព្រោះខុសនឹងទម្រង់ច្បាប់ ។ ក្រុមប្រឹក្សាធម្មនុញ្ញមិនមានសមត្ថកិច្ចបកស្រាយសំណួរ ហើយមាត្រា ១៣៦ ថ្មីនៃរដ្ឋធម្មនុញ្ញអនុញ្ញាតឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយតែរដ្ឋធម្មនុញ្ញ និង ច្បាប់តែប៉ុណ្ណោះ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**
**ប្រធាន**

**ចិន ឈិន**